ចំណាងជើងគម្រោង

# Rise Up!

## កាត់បន្ថយអំពើហិង្សាក្នុងតំបន់ដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជាដូចនេះស្ត្រី និងបុរសអាចក្លាយជាដៃគូដែលមានភាពស្មើគ្នាក្នុងការគ្រប់គ្រងធនធានធម្មជាតិ។



ព្រឹត្តិប័ត្រព័ត៌មាន

### ព័ត៌មានអំពីគម្រោង

Rise Up! គឺជាគម្រោងកាត់បន្ថយអំពើហិង្សាដែលទាក់ទងនិងយេនឌ័រ នៅក្នុងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាដូចនេះស្ត្រីអាចចូលរួមដោយពេលលេញនិងប្រកបដោយសុវត្ថិភាពក្នុងតួនាទីជាអ្នកដឹកនាំ។ គម្រោងនឹងជួយឱ្យស្ត្រីទទួលបានសិទ្ធិលើធនធានធម្មជាតិ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

គម្រោងនេះនិងលើកទឹកចិត្តឱ្យបុរស ស្ត្រី គ្រួសារនិងសហគមន៍យល់ដឹងថាស្ត្រីគឺជាដៃគូសំខាន់និងស្មើភាពគ្នាក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍។

### ដៃគូរបស់គម្រោង

Rise Up! ដឹកនាំដោយអង្គការរីខូហ្វ ធ្វើការយ៉ាងជិតស្និទ្ធិជាមួយអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ( GADC )។ ដៃគូរបស់គម្រោងនៅក្នុងប្រទេសកម្ពុជារួមមានក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី និងកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ។

### សង្ខេបអំពីគម្រោង

គម្រោង និងកាត់បន្ថយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ និងលើកកម្ពស់ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ។

គម្រោងនឹងផ្តោតលើការការពារ និងការប្រាស់ប្តូរអាកប្បកិរិយា និងឥរិយាបថនៅកម្រិតបុគ្គល អន្តរបុគ្គល និងកម្រិតសហគមន៍

គម្រោងនេះគាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ( USAID ) តាមរយៈជំនួយដែលគ្រប់គ្រងដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ ( IUCN )




## តំបន់គោលដៅរបស់គម្រោង

Rise Up! សកម្មភាពនឹងអនុវត្តនៅក្នុងសហគមន៍ព្រៃឈើចំនួន៣ និងសហគមន៍តំបន់ការពារធម្មជាតិចំនួន៥ សហគមន៍។ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិគឺជាគំរូព្រៃសហគមន៍ចំនួន២ ដែលទទួលស្គាល់ស្របច្បាប់ដោយរដ្ឋាភិបាលកម្ពុជា។ សហគមន៍គោលដៅទាំង៨ នេះដឹកនាំដោយគណៈកម្មការសហគមន៍ព្រៃឈើដែលស្ត្រីមានតួនាទីជាដឹកនាំ។

### ខេត្តពោធិ៍សាត់

- សហគមន៍តំបន់ការពារធម្មជាតិរាំងក្វាវ នៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
- សហគមន៍តំបន់ការពារធម្មជាតិទំព័រក្នុងដែនជម្រកភ្នំសំកុស
- សហគមន៍តំបន់ការពារធម្មជាតិកោះទន្លេក្រាស់ក្នុងតំបន់បបនីយជីវៈមណ្ឌលបឹងទន្លេសាប
- សហគមន៍ព្រៃឈើអូរបាក់ត្រា

### ខេត្តកំពង់ឆ្នាំង

- សហគមន៍ព្រៃឈើស្ទឹងសាច់សនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
- សហគមន៍ព្រៃឈើពេជ្រចង្វា ល្អឆើតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
- សហគមន៍តំបន់ការពារធម្មជាតិភ្នំជើងលៀងក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
- សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្មនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់

## ហេតុអ្វី Rise Up សំខាន់សម្រាប់ប្រទេសកម្ពុជា

សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិសំខាន់សម្រាប់ជីវៈចម្រុះ។ នៅក្នុងប្រទេសកម្ពុជា សហគមន៍ព្រៃឈើគឺជាចំណុចអាទិភាពរបស់រដ្ឋាភិបាលក្នុងការ៖

- លុបបំបាត់ភាពក្រីក្រ
- លើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព
- ផ្តល់ការបែងចែកផលប្រយោជន៍ដោយស្មើរភាព

ស្ត្រីត្រូវតែជាដៃគូស្មើគ្នាក្នុងការគ្រប់គ្រងតំបន់ព្រៃឈើសហគមន៍ ដូចជាសហគមន៍ព្រៃឈើ និងសហគមន៍ តំបន់ការពារធម្មជាតិ។ ប៉ុន្តែស្ត្រីជួបប្រទះបញ្ហាប្រឈមពីគ្រួសារសហគមន៍នៅពេលដែលពួកគេចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់របស់គេ។ ហេតុដូចនេះធ្វើឱ្យស្ត្រីងាយនឹងទទួលនូវពាក្យសម្តីមិនសមរម្យ ការបៀតបៀនរាងកាយ សតិអារម្មណ៍ និងមាក់ងាយផ្លូវភេទ។

## តើ Rise Up នឹងធ្វើអ្វីខ្លះ?

គម្រោងនេះនឹងកាត់បន្ថយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ និងលើកកម្ពស់ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ។ ផ្តោតលើការការពារ និងការប្រាស់ប្តូរអាកប្បកិរិយា និងឥរិយាបថនៅកម្រិតបុគ្គល អន្តរបុគ្គល និងកម្រិតសហគមន៍។ បុរសក៏មានការចូលរួមនៅក្នុងដំណើរការនេះដែរ។

យុទ្ធនាការសម្រាប់ការផ្លាស់ប្តូរវិជ្ជមាននឹងដឹកនាំដោយសមាជិកសហគមន៍ព្រៃឈើ សមាជិកសហគមន៍តំបន់ការពារធម្មជាតិ និងសមាជិកបណ្តាញស្ត្រី។

### សកម្មភាពសំខាន់ៗនៅក្នុងគម្រោង Rise Up!

គម្រោងនឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយដើម្បីចែករំលែកពីគោលបំណងនៃគម្រោងជាមួយបុគ្គលិក និងអ្នកពាក់ព័ន្ធនៅក្នុងកម្រិតថ្នាក់ជាតិ ក្រោមជាតិ និងសហគមន៍

- កសាងសមត្ថភាពសមាជិកបណ្តាញក្នុងការការពារអំពើហិង្សាទាក់ទងនិងយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រតាមរយៈយុទ្ធនាការ។

- ផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកទៅលើគោលការណ៍សំខាន់ៗនិងវិធីសាស្ត្រដើម្បីធានាថាបុគ្គលិកអនុវត្តគម្រោងយល់ពីគម្រោងនិងមានជំនាញក្នុងការអនុវត្ត។

- ពង្រឹងកិច្ចសហការអន្តរវិស័យដើម្បីចែករំលែកពីទំនាក់ទំនងរវាងអំពើហិង្សាទាក់ទងនិងយេនឌ័រ និងបរិស្ថាន

- រៀបចំជាការវាយតម្លៃយេនឌ័រនៅក្នុងតំបន់គោលដៅនីមួយៗ និងសរសេរជារបាយការណ៍

- ប្រើប្រាស់វេទិកាថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិដើម្បីចែករំលែកពីមេរៀនដែលផ្តល់ប្រយោជន៍ដល់សហគមន៍ផ្សេងទៀតដែលទាក់ទងនិងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម។

- រៀបចំនិងផ្តល់ជាវគ្គបណ្តុះបណ្តាលទៅដល់សមាជិកសហគមន៍ព្រៃឈើព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ



## តើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ?

សមាជិកសហគមន៍ចំនួន១២០០ នាក់ដែលចូលរួមនៅក្នុងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិជាអ្នកទទួលបានផលប្រយោជន៍ដោយផ្ទាល់។ សមាជិកសហគមន៍ព្រៃឈើ និង

សហគមន៍តំបន់ការពារធម្មជាតិផ្សេងទៀត និងស្ត្រី ដែលបានយល់ដឹងពីប្រយោជន៍នៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនឹងទទួលបានផលប្រយោជន៍ដោយប្រយោលពីគម្រោង។

## ម្ចាស់ជំនួយរបស់គម្រោង

Rise Up! គឺជាគម្រោងមួយក្នុងចំណោមគម្រោងឈ្នះទាំង៥ នៃការប្រកួតប្រជែង ឆ្នាំ២០២២ របស់ជំនួយ ភាពធន់បរិយាប័ន្ន និងនិរន្តរភាពបរិស្ថាន (RISE)។ ជំនួយ RISE ទទួលបានថវិកាគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលគ្រប់គ្រងដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ

## ថវិកានិងពេលវេលា

ថវិកាសរុបសម្រាប់ការអនុវត្តគម្រោង Rise Up មានចំនួន

**៣៩៩,៩៨០**
ដុល្លាអាមេរិក ដែលអនុវត្តន៍

**រយៈពេល២៤ ខែ**
ចាប់ផ្តើមពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៣។

## ទំនាក់ទំនង

**រីខូហ្វកម្ពុជា**
រដ្ឋបាលព្រៃឈើ អាគារលេខ ៤0 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២,
ខណ្ឌដូនពេញ, ភ្នំពេញ, កម្ពុជា
+855 (0) 23 988 784, Cambodia@recoftc.org